**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៧១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតវិទ្យាស្ថាននាវាចរណ៍កម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀប-ចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១:_**

ត្រូវបានបង្កើតវិទ្យាស្ថាននាវាចរណ៍កម្ពុជា ហៅកាត់ថា វ.ន.ក ជាភាសាអង់គ្លេស Cambodian Maritime Institute (C.M.I) ដើម្បីបណ្តុះបណ្តាលធនធានមនុស្សលើវិស័យនាវាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## រចនាសម្ព័ន្ធ និងបេសកកម្ម

**មាត្រា ២:_**

វ.ន.ក ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តភ្នំពេញ ដោយមានការសហការជាមួយកំពង់ផែស្វយ័តក្រុងព្រះសីហនុ ហើយស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

វ.ន.ក មានអាស័យដ្ឋាន លេខ 0២ ផ្លូវបក្សីចាំក្រុង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ៣:_**

វ.ន.ក ដឹកនាំដោយនាយក ០១ (មួយ) រូប អមដោយនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ វ.ន.ក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៤:_**

វ.ន.ក មានបេសកកម្មបណ្តុះបណ្តាលលើវិស័យនាវាចរណ៍កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ ។ ទៅថ្ងៃអនាគត វ.ន.ក អាចពង្រីកកម្រិតបណ្តុះបណ្តាលរបស់ខ្លួនដល់ថ្នាក់ក្រោយឧត្តមសិក្សា ។

**មាត្រា ៥:_**

វ.ន.ក មានប្រាំមហាវិទ្យាល័យ ÷

- មហាវិទ្យាល័យវិទ្យាសាស្ត្របើកបរនាវាផ្លូវសមុទ្រ

- មហាវិទ្យាល័យវិទ្យាសាស្ត្របើកបរនាវាផ្លូវទឹកក្នុងប្រទេស
- មហាវិទ្យាល័យវិទ្យាសាស្ត្រគ្រប់គ្រងវិស័យដឹកជញ្ជូន
- មហាវិទ្យាល័យវិទ្យាសាស្ត្រគ្រប់គ្រង និងប្រតិបត្តិការផែ
- មហាវិទ្យាល័យយន្តសាស្ត្រ និងសំណង់នាវា ។

## ជំពូកទី ៣

## កម្មវិធីសិក្សា លក្ខខណ្ឌជ្រើសរើស និងការផ្តល់សញ្ញាបត្រ

**មាត្រា ៦:_**

ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការរៀបចំកម្មវិធីសិក្សា និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន តាមសំណើរបស់ **វ.ន.ក** ។

**មាត្រា ៧:_**

លក្ខខណ្ឌនៃការជ្រើសរើសនិស្សិតអោយចូលរៀននៅ **វ.ន.ក** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដោយអនុលោមទៅតាមបទដ្ឋាន ស្តីពីការកំណត់លក្ខខណ្ឌនៃការចូលរៀននៅឧត្តមសិក្សា ។

**មាត្រា ៨:_**

និស្សិតដែលបានរៀនចប់តាមកម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សានៅ **វ.ន.ក** ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយវិទ្យាស្ថាននាវាចរណ៍កម្ពុជា ហើយត្រូវទទួលស្គាល់ពីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអប់រំ យុវជន និងកីឡា ។

## ជំពូកទី ៤

## ប្រភពធនធាន

**មាត្រា ៩:_**

**វ.ន.ក** មានប្រភពធនធានដូចខាងក្រោម ÷

- ថវិកាជាតិ ដែលជាឧបសម្ព័ន្ធក្នុងកញ្ចប់ថវិការបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- ថវិកា ដែលស្ថិតក្នុងកញ្ចប់មូលនិធិរបស់កំពង់ផែស្វយ័តភ្នំពេញ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ
- ការបង់ថ្លៃបណ្តុះបណ្តាល
- ហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍនានា បរិច្ចាគរបស់សប្បុរសជន និងជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល ។

**វ.ន.ក** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង ឬក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០:_**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១:_**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**